## ខ្លឹមសារសង្ខេបសាលដីកាលេខ១០៤ (សាលាឧទ្ធរណ៍រាជធានីភ្នំពេញ) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២

**ពាក្យគន្លឹះ៖** មនុស្សឃាដគិតទុកជាមុន,ពេលប្រព្រឹត្តមិនបាននៅទីតាំង,អនីតិជន,សវនាការកំបាំងមុខ។

**កាលបរិច្ឆេទ៖** សាលក្រមជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ខែឧសភាឆ្នាំ២០១១, សំណុំរឿងឧទ្ធរណ៍ខែតុលា ឆ្នាំ២០១២។ សវនាការខែតុលា ឆ្នាំ២០១២ និងថ្ងៃចេញសាលដីកាខែវិច្ឆិកា២០១២។

**អង្គហេតុនិងសេចក្តីសម្រេច៖** នេះជាបណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជនម្នាក់ (អនីតិជនម្នាក់) ប្រឆាំងនឹងសាលក្រមលេខ៤៨ (ជ) ចុះថ្ងៃទី១២ ឧសភាឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ។ សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ៤៦ក្រII ចុះថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០១២។ ពិរុទ្ធជន៦រូបទៀត (ម្នាក់ជាអនីតិជន)បានប្តឹងទាស់ប្រឆាំងសាលដីកាសាលាឧទ្ធរណ៍លេខ៤៦ក្រII ចុះថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០១២។

មេធាវីតំណាងអះអាងថា កូនក្តីមិនបានប្រព្រឹត្ត។ របាយការណ៍ប៉ូលីសគឺធ្វើតាមការលីរបស់ប្រជាពលរដ្ឋនៅតុកាហ្វេ..។ រីឯព្រះរាជអាជ្ញាស្នើឲ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាចុះ (ទំ.៥)។

**សំអាងហេតុ៖**...៣.*មេធាវីការពារឲ្យជនជាប់ចោទបានលើកឡើងថាកូនក្តីខ្លួនមិនបានប្រព្រឹត្តបទមនុស្សឃាតគិតទុកជាមុនទេ ការដែលលោកមេធាវីសន្និដ្ឋានការពារនេះ សាលាដំបូងបានពិចារណារួចអស់ហើយ។..***៥***-ជនជាប់ចោទទាំងអស់ពុំបាននាំនៅភស្តុតាងដោះបន្ទុក ដែលអាចឲ្យពិចារណាបានឡើយពីការរួចផុតពីបទចោទប្រកាន់*។

**កំណត់សំគាល់៖** ទីនេះ វាពាក់ព័ន្ធនឹងបន្ទុកនិងកម្រិតនៃភស្តុតាង (burden and standard of proof)។ តាមច្បាប់និងឲ្យស្របតាមគោលការណ៍សន្និតិជាមុនមិនមានទោស ជនសង្ស័យមិនមានបន្ទុកបង្ហាញភស្តុតាងដោះបន្ទុកទេ ក៏ប៉ុន្តែបង្ហាញភស្តុតាងអំពីការដោះសារ (excuses) (ដូចជាថាគាត់មិននៅទីកន្លែងកើតហេតុ)។ ការបង្ហាញដោះបន្ទុក ដោយឲ្យជនសង្ស័យបង្ហាញអំពីជាតុផ្សំបទល្មើសនោះ មិនអាចទៅរួចទេ។

**សំណួរអាចលើកឡើង៖**អ្វីទៅជាភស្តុតាងដោះបន្ទុក?

**អ្វីត្រូវអានបន្ថែម៖** បន្ទុកនិងកម្រិតភស្តុតាង,គោលការណ៍សន្និតិមិនមានទោសនិងការដោះសារ។ សម្រាប់ខ្លឹមសារសង្ខេបសាលក្រមលេខ៤៨(ជ)ឆ្នាំ២០១១។